ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ..........

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# បំភ្លឺករណីនាំចេញខ្សាច់ស(ខ្សាច់ស៊ីលីកា) ចេញទៅក្រៅប្រទេស

កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ កន្លងទៅនេះ ក្រសួងរ៉ែនិងថាមពលបានទទួលលិខិតរបស់ឯកឧត្តម សុន ឆ័យ អ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ និងជាអនុប្រធានគណៈកម្មការទី២ នៃរដ្ឋសភា បានផ្ញើតាមរយៈ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រសួងបង្ហាញព័ត៌មាន និងឯកសារផ្លូវការទាក់ទងទៅនឹងការនាំខ្សាច់ស (ខ្សាច់ស៊ីលីកា) ចេញទៅក្រៅប្រទេស។ ក្រសួងរ៉ែនិងថាមពល សូមជម្រាបជូនសាធារណជន និងបណ្តាសារព័ត៌មានមេត្តាជ្រាបថា នៅថ្ងៃនេះ ក្រសួងរ៉ែនិងថាមពលបានផ្ញើរួចរាល់នូវឯកសារដែលឯកឧត្តម ស៊ុន ឆ័យ ស្នើសុំ និងសូមបញ្ជាក់ជូនឱ្យជ្រាបច្បាស់ថា ខ្សាច់សមិនមែនជាប្រភេទខ្សាច់សំណង់ទូទៅ ឬខ្សាច់ល្បាយភក់ទេ។ ខ្សាច់សជាប្រភេទធនធានរ៉ែ ដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផលិតកែវ និងផលិតផលកញ្ចក់ផ្សេងៗ។ ការគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់សមានបទដ្ឋានបច្ចេកទេស និងរបបសួយសារធនធានរ៉ែខុសគ្នាពីខ្សាច់សំណង់ ឬខ្សាច់ល្បាយភក់។ កន្លងមកក្រសួងរ៉ែនិងថាមពលពុំដែលចេញលិខិតបទដ្ឋានគតិយុត្តណាមួយស្តីពីការហាមឃាត់ក្នុងការនាំចេញខ្សាច់សទេ។ ទន្ទឹមនឹងនេះដែរ លិខិតរដ្ឋបាល លេខ ២០៧៥រ.ថ.រស ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ចេញដោយក្រសួងរ៉ែនិងថាមពល គឺជាឯកសាររដ្ឋបាលរបស់ស្ថាប័ននីតិប្រតិបត្តិ ដែលគ្មានបែបបទរដ្ឋបាលណាតម្រូវឱ្យគ្រប់ស្ថាប័នត្រូវចម្លងជូនឯកឧត្តម សុន ឆ័យ ឡើយ។ ពាក់ព័ន្ធនឹងការទាមទារផ្តល់ឯកសារលម្អិតបន្ថែមទៀត ក្រសួងរ៉ែនិងថាមពលសូមធ្វើការបំភ្លឺ ដូចខាងក្រោម៖

បច្ចុប្បន្ននេះក្រសួងរ៉ែនិងថាមពល បានផ្តល់អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មខ្សាច់ស ឱ្យក្រុមហ៊ុនចំនួន០២ គឺក្រុមហ៊ុនម៉ុង ឫទ្ធី គ្រុប (MONG RETHTHY GROUP Co., Ltd.) និងក្រុមហ៊ុន ស៊ីបែលកូ (ខេមបូឌា) ខមភេនី លីមីតធីត (Sibelco (Cambodia) Company Limited) ដែលបានប្តូរនាមករណ៍មកជាក្រុមហ៊ុនស៊ីលីកាសឺវីស (កាំបូដ) ឯ.ក (Silica Service (Cambodge) Co., Ltd.) វិញ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៦។ ដោយឡែក ការដ្ឋានអាជីវកម្មខ្សាច់សរបស់ក្រុមហ៊ុនទាំង០២គឺស្ថិតនៅលើដីគោក ដែលត្រូវបកយកស្រទាប់ខ្សាច់សក្នុងជម្រៅចន្លោះពី ០,៣០ម៉ែត្រ ទៅ ២ម៉ែត្រ តែប៉ុណ្ណោះ ដូច្នេះមិនតម្រូវឱ្យមានការសិក្សាវាយតម្លៃផលសាស្ត្រ និងជលផល ដោយឡែកទេ។ រាល់ការសិក្សាទាំងអស់ត្រូវបានដាក់ចូលក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ហៅកាត់ថា EIA។ ឯកសារ EIA នេះ គឺមិនស្ថិតក្នុងដែនគ្រប់គ្រងរបស់ក្រសួងទេ។ ចំពោះតួលេខសរុបនៃការនាំចេញខ្សាច់ស គិតចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៦ រហូតមកដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ នេះមាន ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប ចំនួន ៥៤.១០០ MT (ហាសិបបួនពាន់មួយរយតោន) និងក្រុមហ៊ុន ស៊ីលីកាស៊ីវែស (កាំបូជ) ឯ.ក ចំនួន ១០៤.០០០ MT (មួយរយបួនពាន់តោន)។

ការគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់សដើម្បីនាំចេញ មានការពាក់ព័ន្ធសមត្ថកិច្ចទទួលខុសត្រូវច្រើនស្ថាប័ន។ ក្រសួងរ៉ែនិងថាមពលគ្រប់គ្រងតែលើការងារបច្ចេកទេសនៃការធ្វើអាជីវកម្មរ៉ែខ្សាច់ស និងការចេញលិខិតអនុញ្ញាតនាំចេញ (Export Certificate) តែប៉ុណ្ណោះ។ លិខិតអនុញ្ញាតនាំចេញនេះគឺជាឯកសារសំខាន់សម្រាប់ការកំណត់ និងបញ្ជាក់ពីការបានបង់ចំណូលសួយសាររ៉ែ មុននឹងអនុញ្ញាតឱ្យនាំចេញខ្សាច់ស។ ក្នុងការនាំចេញមួយលើកៗ ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំអនុញ្ញាតធ្វើការនាំចេញមកក្រសួងរ៉ែនិងថាមពល ដោយបញ្ជាក់អំពីបរិមាណនិងប្រទេសដែលជាគោលដៅនាំចេញ។ ក្រៅពីនេះ ក្រុមហ៊ុនត្រូវបំពេញបែបបទនៅច្រកនាំចេញតាមនីតិវិធីជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងៗទៀត។ ដូចនេះឯកសារដែលឯកឧត្តម សុន ឆ័យ ស្នើសុំផ្សេងទៀត រួមមាន ប្រតិវេទន៍ចូល ប្រតិវេទន៍ចេញ វិក្កយបត្របញ្ជាក់ការផ្ទុកទំនិញ បញ្ជីការផ្ទុកដាក់ទំនិញ វិក្កយបត្រពាណិជ្ជកម្ម និងវិក្កយបត្រកំណត់ពន្ធគយ មិនស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងរ៉ែនិងថាមពលទេ។ ក្រសួងរ៉ែនិងថាមពលមិនធ្វើអាជីវកម្មលក់ខ្សាច់ទេ ក្រសួងមានភារកិច្ចត្រឹមប្រមូលសួយសារអនុលោមតាមអត្រាសួយសារដែលបានកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែប៉ុណ្ណោះ។ ចំណូលសួយសារពីខ្សាច់សនាំចេញ គិតចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៦ រហូតមកដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ នេះ មានចំនួន $៤៧៤.៣០០ (បួនរយចិតសិបបួនពាន់បីរយ ដុល្លារអាមេរិក) ចំណូលនេះជាចំណូលសួយសារលើវត្ថុធាតុដើមប្រមូលតាមរយៈក្រសួងរ៉ែនិងថាមពល ដោយមិនរួមបញ្ចូលចំណូលពន្ធអាករផ្សេងៗទៀតឡើយ។

ចំពោះឯកសារដែល ឯកឧត្តម ស៊ុន ឆ័យ ស្នើសុំមកក្រសួងរ៉ែនិងថាមពល មានឯកសារជាច្រើនដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពលឡើយ។ ក្នុងការបំភ្លឺដល់ឯកឧត្តម សុន ឆ័យ ក្រសួងរ៉ែនិងថាមពលក៏បានភ្ជាប់ជូននូវឯកសារមួយចំនួន មានដូចជា លិខិតលេខ២០៧៥រ៉ថ.រស ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មខ្សាច់ស ចំនួន ០២ ច្បាប់ លិខិតអនុញ្ញាតនាំចេញ (Export Certificate) ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ចំនួន ១៧ ច្បាប់ និងលិខិតចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ចំនួន ០២ ច្បាប់។

សូមសាធារណជន ជាពិសេសអ្នកសារព័ត៌មានជាតិនិងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។